វីរុសកូរ៉ូណាប្រភេទថ្មី

Washington State Department of Health

តើវីរុសកូរ៉ូណាប្រភេទថ្មីគឺជាអ្វី?

វីរុសកូរ៉ូណាប្រភេទថ្មី (COVID-19) គឺជាប្រភេទវីរុសដែលទើបនឹងឆ្លងរាលដាលដល់មនុស្សចាប់តាំងពីខែធ្នូ ឆ្នាំ 2019 ។ អ្នកជំនាញផ្នែកសុខភាពមានការព្រួយបារម្ភព្រោះគេមិនសូវដឹងអំពីវីរុសថ្មីនេះទេ ហើយវាមានសក្តានុពលបង្កឱ្យមានជំងឺធ្ងន់ធ្ងរ និងរលាកសួតលើមនុស្សមួយចំនួន។

តើវីរុសកូរ៉ូណាប្រភេទថ្មីនេះឆ្លងរាលដាលយ៉ាងដូចម្តេច?

អ្នកជំនាញផ្នែកសុខភាពនៅតែកំពុងសិក្សាលម្អិតអំពីរបៀបដែលវីរុសកូរ៉ូណាថ្មីនេះរីករាលដាល។ វីរុសកូរ៉ូណាផ្សេងទៀតឆ្លងរាលដាលពីអ្នកដែលបានឆ្លងទៅមនុស្សផ្សេងទៀតតាមរយៈ៖

- ខ្យល់ដោយការក្អក និងកណ្តាស់
- ទំនាក់ទំនងផ្ទាល់ខ្លួនជិតស្និទ្ធ ដូចជាការប៉ះ ឬការចាប់ដៃ
- ការប៉ះវត្ថុ ឬផ្ទៃណាមួយដែលមានផ្ទុកវីរុសលើវា បន្ទាប់មកប៉ះមាត់ ច្រមុះ ឬភ្នែករបស់អ្នក
- ក្នុងករណីដ៏កម្រ ប៉ះនឹងលាមក

តើវីរុសកូរ៉ូណាប្រភេទថ្មីមានលក្ខណៈធ្ងន់ធ្ងរកម្រិតណា?

ក្រុមអ្នកជំនាញកំពុងសិក្សាអំពីកម្រិតនៃជំងឺពីមេវីរុសកូរ៉ូណាប្រភេទថ្មីនេះ។ ករណីដែលបានរាយការណ៍មានចាប់ពីជំងឺស្រាល (ស្រដៀងនឹងជំងឺផ្តាសាយធម្មតា) រហូតដល់ជំងឺរលាកសួតធ្ងន់ធ្ងរដែលតម្រូវឲ្យចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ រហូតមកដល់ពេលនេះការស្លាប់ត្រូវបានគេរាយការណ៍ជាចម្បងចំពោះមនុស្សវ័យចំណាស់ដែលមានស្ថានភាពសុខភាពផ្សេងទៀត។

តើរោគសញ្ញាមានអ្វីខ្លះ?

អ្នកដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានវីរុសកូរ៉ូណាប្រភេទថ្មីបានរាយការណ៍ពីរោគសញ្ញាដែលអាចលេចឡើងក្នុងរយៈពេលតិចបំផុត 2 ថ្ងៃ ឬក្នុងរយៈពេល 14 ថ្ងៃ បន្ទាប់ពីការប៉ះពាល់នឹងវីរុស៖

ក្រុនក្តៅ

ក្អក

ពិបាកដកដង្ហើម



តើនរណាជាអ្នកប្រថុយនឹងវីរុសកូរ៉ូណាប្រភេទថ្មី?

នៅពេលនេះមានករណីបុគ្គលមួយចំនួនតូចនៅសហរដ្ឋអាមេរិក។ ដើម្បីកាត់បន្ថយហានិភ័យនៃការរាលដាល មន្ត្រីសុខាភិបាលកំពុងធ្វើការជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ដើម្បីកំណត់ និងវាយតម្លៃករណីដែលសង្ស័យណាមួយភ្លាមៗ។

អ្នកធ្វើដំណើរទៅ និងមកពីតំបន់មួយចំនួននៅពិភពលោកអាចប្រឈមនឹងហានិភ័យខ្ពស់។ សូមមើល wwwnc.cdc.gov/travel សម្រាប់ការណែនាំអំពីការធ្វើដំណើរចុងក្រោយបំផុតពី CDC ។

តើខ្ញុំអាចការពារពីការឆ្លងវីរុសកូរ៉ូណាប្រភេទថ្មីបានដោយរបៀបណា?

ប្រសិនបើអ្នកកំពុងធ្វើដំណើរទៅបរទេស (ទៅប្រទេសចិន ប៉ុន្តែក៏ទៅកន្លែងផ្សេងទៀត) ធ្វើតាមការណែនាំរបស់ CDC៖ wwwnc.cdc.gov/travel។

ឥឡូវនេះ វីរុសកូរ៉ូណាប្រភេទថ្មីមិនត្រូវបានរីករាលដាលយ៉ាងទូលំទូលាយនៅសហរដ្ឋអាមេរិកទេ ដូច្នេះមិនមានការប្រុងប្រយ័ត្នបន្ថែមទៀតដែលត្រូវបានណែនាំសម្រាប់សាធារណៈជនទូទៅទេ។ ជំហានដែលអ្នកអាចអនុវត្ត ដើម្បីបង្ការការរីករាលដាលនៃជំងឺផ្តាសាយ និងជំងឺផ្តាសាយទូទៅក៏នឹងជួយបង្ការវីរុសកូរ៉ូណានេះផងដែរ៖

- លាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹក។ បើមិនមាន សូមប្រើទឹកអនាម័យសម្រាប់លាងដៃ។

- ចៀសវាងប៉ះភ្នែក ច្រមុះ ឬមាត់របស់អ្នកដោយប្រើដៃដែលមិនលាងសម្អាត
- ចៀសវាងការទាក់ទងជាមួយមនុស្សដែលឈឺ
- នៅផ្ទះនៅពេលអ្នកឈឺ ហើយចៀសវាងមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដទៃ
- បិទមាត់ / ច្រមុះរបស់អ្នកជាមួយនឹងក្រដាសជូតមាត់ ឬដៃអាវពេលក្អក ឬកណ្តាស់

បច្ចុប្បន្ននេះ មិនមានវ៉ាក់សាំងណាមួយអាចបង្ការការឆ្លងវីរុសកូរ៉ូណាប្រភេទថ្មីនេះបានទេ។

តើវីរុសកូរ៉ូណាប្រភេទថ្មីត្រូវបានព្យាបាលយ៉ាងដូចម្តេច?

មិនមានថ្នាំដែលត្រូវបានអនុម័តជាពិសេសសម្រាប់វីរុសកូរ៉ូណានេះទេ។ មនុស្សភាគច្រើនដែលមានជំងឺវីរុសកូរ៉ូណាស្រាលនឹងជាសះស្បើយដោយខ្លួនឯងដោយការផឹកទឹកឱ្យបានច្រើន សម្រាក និងលេបថ្នាំបំបាត់ការឈឺចាប់ និងក្តៅខ្លួន។ ទោះយ៉ាងណាក៏ដោយ ករណីខ្លះវិវត្តទៅជាជំងឺរលាកសួត ហើយត្រូវការការថែទាំវេជ្ជសាស្ត្រ ឬសម្រាកនៅមន្ទីរពេទ្យ។

សម្រាប់ព័ត៌មានបន្ថែម៖ www.doh.wa.gov/coronavirus

បានធ្វើបច្ចុប្បន្នភាព 1/24/2020 Khmer

សម្រួលពីសុខភាពសាធារណៈ – Seattle & King County